ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរំលាយសហគ្រាសសាធារណៈ

## ភ្នាក់ងារកម្ពុជានាវាចរ ហៅថា "កាំសាប"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបញ្ចប់បេសកកម្ម និងរំលាយសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋឈ្មោះ **ភ្នាក់ងារកម្ពុជានាវាចរ** ហៅថា **កាំសាប** ដែលបានបង្កើតឡើងតាមអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ "កាំសាប" ចាប់ពីម៉ោងសូន្យ នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ នេះតទៅ។

**មាត្រា២.-**

ត្រូវបានប្រគល់ភារកិច្ចជូនក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីសម្របសម្រួលផ្ទេរក្របខ័ណ្ឌនិយោជក និងនិយោជិតរបស់ **កាំសាប** តាមលទ្ធភាព និងតម្រូវការជាក់ស្តែង ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ឬកំពង់ផែស្វយ័តភ្នំពេញ ឬកំពង់ផែស្វយ័តក្រុងព្រះសីហនុ។

**មាត្រា៣.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងជាអាណាព្យាបាលហិរញ្ញវត្ថុ ត្រូវសម្របសម្រួលជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងឋានៈជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងជាអាណាព្យាបាលបច្ចេកទេស ផ្ទេរទ្រព្យសម្បត្តិរបស់ **កាំសាប** រួមមានអចលនវត្ថុ, ចលនវត្ថុ, រតនវត្ថុ និងកាតព្វកិច្ចហិរញ្ញវត្ថុដទៃទៀតរួមទាំងបំណុលត្រូវទារ និងបំណុលត្រូវសង តាមនីតិវិធីជាធរមាន។

**មាត្រា ៤.-**

ត្រូវបាននិរាករណ៍នូវលិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម÷

- អនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ "កាំសាប"
- អនុក្រឹត្យលេខ ៣០៦ អនក្រ.តត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ "កាំសាប"
- លិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១ កើត ខែ មាឃ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ